អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

អង្គបុរេជំនុំជម្រះ

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ៣០ មេសា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2008
ម៉ោង (Time/Heure): 15h40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

## សេចក្តីសម្រេចលើសំណើសុំរបស់ អៀង សារី ដែលស្នើសុំការអនុញ្ញាតឲ្យផ្អាកការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះការឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំឲ្យមានដីកាណែនាំដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីអនុញ្ញាតឲ្យ អៀង សារី បានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G.KARNAVAS

១- **អង្គបុរេជំនុំជម្រះ** ទទួលបាន "សំណើរបស់ **អៀង សារី** ដែលស្នើសុំការអនុញ្ញាតឱ្យផ្អាកការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនដែលបានសុំឱ្យឃុំខ្លួនក្នុងផ្ទះ ជំនួសឱ្យការឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក និងសំណើសុំឱ្យមានដីកាណែនាំដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីអនុញ្ញាតឱ្យ **អៀង សារី** បានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យក្នុងដំណាក់កាលស៊ើបអង្កេត" ដែលបានដាក់ចូលមកជាភាសាអង់គ្លេស នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៨ *("សំណើ")* ។ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៨ សហមេធាវីការពារក្តីបានដាក់ព័ត៌មានបន្ថែមដើម្បីគាំទ្រ *សំណើ* នេះ។

២- នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹង *សំណើ* នេះ។

៣- នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានអញ្ជើញសហមេធាវីការពារក្តីឱ្យដាក់សារណាតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា។

៤- នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ សហមេធាវីការពារក្តីបានដាក់សារណាតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា។

៥- អង្គបុរេជំនុំជម្រះពុំបានទទួលសារណាពីមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

៦- ក្នុង *សំណើ* នេះ សហមេធាវីការពារក្តីលើកឡើងថា នៅក្នុងបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ពួកគេ "បានស្នើសុំកែប្រែលក្ខខណ្ឌឃុំខ្លួន ទៅឃុំខ្លួនក្នុងផ្ទះវិញ"។ ប៉ុន្តែដោយសារសុខភាពចុះដុនដាបរបស់លោក **អៀង សារី** ឥឡូវនេះ ជំនួសឱ្យការឃុំខ្លួនក្នុងផ្ទះ សហមេធាវីការពារក្តី "ស្នើសុំឱ្យ **អៀង សារី** បានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ រហូតដល់គាត់ជាសះស្បើយទាំងស្រុងពីបញ្ហាសុខភាពបច្ចុប្បន្នរបស់គាត់ឡើងវិញ"។ ហេតុដូច្នេះ សហមេធាវីការពារក្តីស្នើឱ្យអង្គបុរេជំនុំជម្រះផ្អាកការពិចារណាលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហើយស្នើឱ្យអង្គបុរេជំនុំជម្រះចេញដីកាណែនាំដល់សហចៅក្រមស៊ើបអង្កេតដើម្បីអនុញ្ញាតឱ្យ **អៀង សារី** បានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។

៧- អង្គបុរេជំនុំជម្រះមានយុត្តាធិការដោះស្រាយ "រឿងបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ **អៀង សារី**" ដែលបានស្នើសុំកែប្រែលក្ខខណ្ឌឃុំខ្លួន និងស្នើសុំឱ្យផ្អាកការឃុំខ្លួនតាមលក្ខខណ្ឌ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងយកខ្លឹមសារនៃសំណើនេះទៅពិចារណា ដោយដោះស្រាយរឿងបណ្តឹងឧទ្ធរណ៍។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេច:**

១- *បដិសេធសំណើសុំផ្អាកការពិចារណា*

២- *ដោះស្រាយបញ្ហាដែលបានលើកឡើងក្នុងសេចក្ដីសម្រេចនេះនៅក្នុង "រឿងបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ **អៀង សារី**"។*

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

**ប្រាក់ គឹមសាន**